**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

# សេចក្តីប្រកាសពត៌មាន

កម្ពុជាមានកិត្តិយសធ្វើជាម្ចាស់ផ្ទះ របស់អង្គប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានលើកទី ៧ អង្គប្រជុំថ្នាក់រដ្ឋមន្ត្រី អាស៊ានលើកទី ៤ + ៣ (ចិន ជប៉ុន និង កូរ៉េ ) និង កិច្ចប្រជុំ អាស៊ាន + ចិន លើកទី ១ ប្រព្រឹត្តិទៅនៅថ្ងៃទី ១៦ ដល់ ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នៅ ទីក្រុងសៀមរាប ព្រះរាជាណាចក្រកម្ពុជា ។

ប្រទេសទាំងឡាយរបស់សមាគមន៍អាស៊ាន មានគោលបំណងជាច្រើនរួមគ្នា ហើយ ក៏មានការប្រឈមមុខជាច្រើនរួមគ្នាដែរ ។ ទំនាក់ទំនងនៅក្នុងសមាគមន៍អាស៊ាន តែងតែ ប្រព្រឹត្តឡើងដោយការយោគយល់គ្នា និង សហប្រតិបត្តិការជិតស្និទ្ធ ហើយរាល់ការ ប្រឈមមុខទាំងនោះ ប្រទេសទាំងអស់នៅក្នុងក្របខណ្ឌអាស៊ាន ក៏បានរួមគ្នាសំរេច ការងារជាច្រើនផងដែរ ។ បច្ចុប្បន្នកាល ប្រទេសជាសមាជិកអាស៊ាន តែងតែប្រឈមមុខ នឹងបញ្ហាចំបងមួយក្នុងតំបន់ គឺបញ្ហាឧក្រិដ្ឋកម្មឆ្លងដែន ។ ប្រទេសអាស៊ានទាំងអស់ យល់ច្បាស់ថា បញ្ហាមួយនេះ មិនមែនជាបញ្ហាសំរាប់តែកម្ពុជានោះទេ គឺជាបញ្ហារួមសំរាប់ ប្រទេសអាស៊ានទាំងអស់ប្រឈមមុខ ។ ហើយដើម្បីទប់ទល់ និង ប្រយុទ្ធប្រឆាំងប្រកប ដោយប្រសិទ្ធិភាព នៅពេលថ្មីៗនេះ អាស៊ានបានអនុម័តបន្ថែម នូវយន្តការចង្អុលទិសថ្មីដ៏ សំខាន់មួយ គឺ **ធម្មនុញ្ញអាស៊ាន** ។

ក្រុមប្រព្រឹត្តអំពើឧក្រិដ្ឋកម្មអន្តរជាតិទាំងនោះ មានការចាត់តាំងល្អ និង មានគោល បំណងខ្ពស់ ។ ប៉ុន្តែក្រុមប្រទេសជាសមាជិកអាស៊ាន ក៏មានការចាត់តាំងល្អ និង គោល បំណងខ្ពស់ ហើយប្រសើរក្រៃលែង ជាងក្រុមឧក្រិដ្ឋជនទាំងនោះ ។ ធម្មនុញ្ញអាស៊ាន ផ្តល់ជូនប្រទេសអាស៊ាននូវកម្លាំង និង សេចក្តីសំរេចដ៏រឹងមាំ សំរាប់ជំរុញក្រុមអនុវត្តន៍ ច្បាប់របស់អាស៊ានដើម្បីប្រយុទ្ធនិងទប់ស្កាត់ឧក្រិដ្ឋកម្មមានការចាត់តាំងទាំងនោះ។

គោលបំណងអាស៊ានមានន័យច្បាស់ គឺបំបាត់ឧក្រិដ្ឋកម្មអន្តរជាតិឱ្យអស់និន្នាការ គ្រប់ប្រភេទរបស់វា។ ដើម្បីសុវត្ថិភាពនិងស្ថិរភាពរបស់តំបន់អាស៊ានទាំងមូល ប្រទេស សមាជិកអាស៊ានមិនអនុញ្ញាតជាដាច់ខាតឱ្យបំណងរបស់ខ្លួនទទួលបរាជ័យ។ ការរួមគ្នា អនុវត្តន៍នូវគំនិតខាងលើនេះ បង្ហាញពីភាពរឹងមាំរបស់ អាស៊ានឈរលើ " ទស្សនវិស័យ តែមួយ អត្តសញ្ញាណតែមួយ និង សហគមន៍តែមួយ " ។

*********